

១៤

# សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

## និយមន័យ

កុមារ គឺត្រូវបានកំណត់និយមន័យជាអន្តរជាតិថាជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ។

នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ កុមារ ដែលទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នាទៅនឹងនីតិជនដែរ។ ប៉ុន្តែកុមារក៏ត្រូវការការការពារ និងការថែទាំពិសេសដែលស្របទៅតាមអាយុភាពចាស់ទុំ ព្រមទាំងការអភិវឌ្ឍផ្នែកបញ្ញា និងផ្នែកអារម្មណ៍របស់ពួកគេផងដែរ។

ចំណុចនេះបកស្រាយដោយភាពចាំបាច់ពិសេសសម្រាប់អាជ្ញាធររដ្ឋដើម្បី៖

- ការពារការសន្និតទុកជាមុនថាគ្មានទោសចំពោះកុមារទំនាស់នឹងច្បាប់ តាមរយៈការផ្ដល់នូវព័ត៌មានអំពីការអភិវឌ្ឍរបស់កុមារទៅកាន់អាជ្ញាធរ និងតួអង្គពាក់ព័ន្ធ។



- ជូនដំណឹងដល់កុមារដោយផ្ទាល់ និងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានអំពីការចោទប្រកាន់ និងជំហាននីតិវិធីលើពួកគេ និងកាន់តែប្រសើរ បើការជូនដំណឹងនោះអាចធ្វើបានតាមរយៈឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់។
- ផ្ដល់ឱ្យកុមារទំនាស់នឹងច្បាប់នូវជំនួយដោយឥតគិតថ្លៃ និងសមរម្យ ដើម្បីរៀបចំការពារក្ដីរបស់ពួកគេ។
- ការពារសិទ្ធិរបស់កុមារក្នុងការមិនត្រូវបានបង្ខិតបង្ខំឱ្យផ្ដល់សក្ខីកម្ម ឬសារភាពពីពិរុទ្ធភាពរបស់ពួកគេ។
- នាំកុមារដែលទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌមកបង្ហាញខ្លួនចំពោះមុខអាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង "ដោយមិនមានការពន្យារពេល"។
- អនុវត្តដំណើរការនីតិវិធីមួយ ដែលមានបរិយាកាសអាចអនុញ្ញាតឱ្យកុមារដែលរងការចោទប្រកាន់បានយល់ ចូលរួម និងគោរពគោលការណ៍ស្មើភាពគ្នា។
- ផ្ដល់ឱ្យកុមារនូវអ្នកបកប្រែដោយឥតគិតថ្លៃ ប្រសិនបើកុមារមិនចេះភាសា ដែលប្រើប្រាស់ក្នុងសវនាការ។
- ធានាថាឯកជនភាពរបស់កុមារត្រូវបានគោរពនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។ សវនាការរបស់កុមារត្រូវតែដំណើរការជាអសាធារណៈស្របតាមវិធានទូទៅ។
- គោរពសិទ្ធិរបស់កុមារដែលទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌការទទួលបានសវនាការនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។



- បង្ការការដកហូតសេរីភាពរបស់កុមារតាមអំពើចិត្ត និងខុសច្បាប់នៅគ្រប់ពេលវេលាទាំងអស់។
- ហាមឃាត់ការកាត់ទោសប្រហារជីវិត និងការដាក់ពន្ធនាគារអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង។



រដ្ឋក៏ត្រូវបានលើកទឹកចិត្តឱ្យបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់កុមារសមស្របមួយ ដោយមានច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នអនុវត្តជាពិសេសចំពោះកុមារ ដើម្បីធានាថាពួកគេទទួលបានការប្រព្រឹត្តចំពោះខ្លួនស្របទៅនឹងអាយុរបស់ពួកគេ។ រដ្ឋក៏ត្រូវកំណត់អាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយកុមារ ដែលមានអាយុក្រោមការកំណត់នេះ មិនតម្រូវឱ្យទទួលខុសត្រូវឡើយ និងផ្ដល់អាទិភាពដល់វិធានការជំនួសចំពោះដំណើរការនីតិវិធីសម្រាប់កុមារដែលទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។

# ក្របខ័ណ្ឌច្បាប់

## ច្បាប់អន្តរជាតិ



មាត្រា ១៤(៤) នៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា "នីតិវិធីអនុវត្តចំពោះយុវជន យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ" និងទទួលស្គាល់ ព្រមទាំងតម្រូវឱ្យការការពារសិទ្ធិរបស់អនីតិជនដូចដែលមានចែងក្នុងមាត្រា ២៤ (១) នៃកតិកាសញ្ញានេះ។ អនុសញ្ញាស្តីពីសិទ្ធិកុមារក៏បានបញ្ញត្តិដាក់លាក់សម្រាប់ការការពារអនីតិជនក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ច្បាប់ជាតិ

មាត្រា ៣១ និងមាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញចែងយ៉ាងច្បាស់លាស់ថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដូចដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ [...] ។" ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិជាច្រើនទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។ ចុងក្រោយច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ក៏បានកំណត់នូវវិធានដាក់លាក់សម្រាប់ការអនុវត្តចំពោះកុមារទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។




## សារសំខាន់



កុមារគឺជាប្រភេទមួយនៃបុគ្គលដែលងាយរងគ្រោះបំផុត ដោយសារតែអាយុ និងការអភិវឌ្ឍរបស់ពួកគេ។ ឧត្តមប្រយោជន៍ និងសុខុមាលភាពរបស់ពួកគេត្រូវតែជាការពិចារណាចម្បងនៅគ្រប់វិធានការទាំងអស់ រួមទាំងវិធានការ ដែលអនុវត្តដោយស្ថាប័នរដ្ឋ ឬសហគ្រាសឯកជនរបស់រដ្ឋ និងតុលាការ។

ច្បាប់ និងវិធានទាំងឡាយសម្រាប់យុត្តិធម៌កុមារ ដើម្បីអនុវត្តឱ្យគ្រប់ជ្រុងជ្រោយចំពោះកុមារដែលទទួលរងការចោទប្រកាន់ ពីបទព្រហ្មទណ្ឌ ដោយពិចារណាដល់អាយុ ការអភិវឌ្ឍ និងភាពចាស់ទុំរបស់ពួកគេ គឺជាកត្តាដែលសំខាន់បំផុត។ ប្រការនេះធានាថាជីវិតរបស់កុមារទំនាស់នឹងច្បាប់ មិនត្រូវបានប៉ះពាល់ជាអចិន្ត្រៃយ៍ដោយសារអំពើបានប្រព្រឹត្ត នៅអាយុដែលកុមារអាចនៅក្មេងពេកក្នុងការយល់ដឹង ឬក្មេងពេកក្នុងការគ្រប់គ្រងសកម្មភាពរបស់ខ្លួនបាន។





យុត្តិធម៌កុមារ គឺជាមូលដ្ឋានក្នុងការលើកកម្ពស់ស្មារតីនៃការគោរពសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារ ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ និងធានាការធ្វើសមាហរណកម្មមកក្នុងសង្គមវិញដោយជោគជ័យ។

## ដែនកំណត់

យុត្តិធម៌កុមារមិនមានការលើកលែង និងអនុវត្តចំពោះកុមារទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ នៅពេលដែលត្រូវបានចោទប្រកាន់ពីបទល្មើស ដើម្បីចៀសវាងការរើសអើង។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិតម្រូវថា រដ្ឋមិនត្រូវកម្រិតទៅលើការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងនីតិវិធីចំពោះកុមារ ដែលមានអាយុក្រោម ១៦ ឆ្នាំ ឬទាបជាងនេះ ឬដែលអនុញ្ញាតជាពិសេសឱ្យមានប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីប្រព្រឹត្តចំពោះកុមារអាយុ ១៦ ឬ ១៧ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស ដូចគ្នាទៅនឹងនីតិជនផងដែរ ដើម្បីចៀសវាងពីការរើសអើងទៅលើកុមារទាំងនោះ។



ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
Sweden Sverige
People Change the World Diakonia

CC BY NC SA